

# ផ្ការីកផ្ការោយ

ខ្ញុំមានចម្ងល់ឆ្ងល់ក្នុងចិត្ត
ព្រោះដ្បិតឮពាក្យអ្នកខ្លះស្តី
ថាផ្ការីកល្អគួរមេត្រី
រីកហើយរោយខ្ចីគ្មានមេត្តា។
បើគង់តែរោយខំរីកថ្វី
នាំនឹកអាល័យសម្រស់ផ្កា
អាសូរតែអស់អង្គភូមរ៉ា
វិយោគយ៉ាងណាផ្ការោយហើយ។
បើផ្កាចេះរីកមិនចេះរោយ
គួរឱ្យអាណោចយ៉ាងណាអើយ
រីកហើយនៅស្ងៀមផ្ញើកន្តើយ
តើថ្ងៃណាឡើយនឹងមានផ្លែ។
ឱ្យមនុស្សនិងសត្វធ្វើអាហារ
លៀងជន្មជីវ៉ាជាហូរហែរ
បើមានតែផ្កាមិនមានផ្លែ
រុក្ខជាតិច្រើនដែរផុតពូជពង្ស។
បើផ្ការីកហើយមិនរោយរុះ
នៅលុះនិរន្តរ៍អន្លាយលង់
ថ្ងៃណាក៏ឃើញផ្ការញ៉ង់
ទោះល្អឆោមទ្រង់ក៏អស់ន័យ។
ផ្ការីកផ្ការោយតាមធម្មជាតិ
មានជួបមានឃ្លាតមិនលែងអ្វី
ពេលផ្ការីកល្អសាទរខ្ចី
កុំចាំធ្លាក់ដីស្តីថាស្តាយ។
ជីវិតមនុស្សយើងខ្លីសោតសល់
វេលាល្អដល់កុំរាយមាយ
ផ្ការោយរីកវិញជារឿងងាយ
ឱកាសឃ្លាតឆ្ងាយពុំងាយវិល។

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី

